# ទិវាអន្តរជាតិសភានឹងប្រារព្ធធ្វើឡើងនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣




ទិវាអន្តរជាតិសភា នឹងប្រារព្ធធ្វើឡើងនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣

ថ្ងៃពុធ ១១កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣

ទិវាអន្តរជាតិសភានឹងប្រារព្ធធ្វើឡើងនៅថ្ងៃសុក្រទី៣០ ខែមិថុនា ឆ្នាំ២០២៣ ដើម្បីជាកិត្តិយសដល់អភិបាលកិច្ចប្រព័ន្ធសភា។ ទិវាអន្តរជាតិសភាបានប្រារព្ធធ្វើឡើងជាលើកទី១ ដោយសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិក្នុងឆ្នាំ២០១៨។ ទិវាខាងលើទទួលស្គាល់ប្រព័ន្ធដ៏ស្ថិតស្ថេរ និងមានលក្ខណៈពិសេសប្លែកគេនៃប្រជាធិបតេយ្យសភា ថាជាបទដ្ឋានសម្រាប់តំណាងនយោបាយ។ ទិវាមួយនេះក៏ទទួលស្គាល់ពីមធ្យោបាយដែលប្រព័ន្ធសភាអាចធ្វើការស្វ័យវាយតម្លៃដើម្បីវឌ្ឍនភាព រកឱ្យឃើញនូវបញ្ហាប្រឈម និងរិះរកវិធីសាស្ត្រដើម្បីដោះស្រាយបញ្ហាទាំងនោះ។

## ប្រវត្តិនៃទិវាអន្តរជាតិសភា

ទិវាអន្តរជាតិសភា គឺជាពិធីមួយធ្វើឡើងជារៀងរាល់ឆ្នាំ នៃអភិបាលកិច្ចប្រព័ន្ធសភា។ ទិវានេះជាកិត្តិយសដល់តម្លៃជាមូលដ្ឋាននៃប្រព័ន្ធសភា និងជាការប្តេជ្ញារបស់តំណាងនយោបាយទៅកាន់ប្រជាជនរាប់ពាន់លាននាក់។ មហាសន្និបាតអង្គការសហប្រជាជាតិទទួលស្គាល់តួនាទីរបស់សភា ក្នុងការធានានូវការទទួលខុសត្រូវខ្ពស់ជាងមុន និងតម្លាភាពរបស់ប្រជាជននៅក្នុងអំណាច។ ទិវាអន្តរជាតិសភា ជាការកត់សម្គាល់នូវខួបអនុស្សាវរីយ៍របស់សហភាពអន្តរសភា( IPU ) ដែលបង្កើតឡើងនៅក្នុងឆ្នាំ១៨៨៩ ក្នុងនាមជាតំណាងផ្លូវការរបស់អភិបាលកិច្ចប្រព័ន្ធសភា។ IPU គឺជាអង្គការសភាសកលមួយដែលធ្វើការងារលើការលើកកម្ពស់អភិបាលកិច្ចប្រជាធិបតេយ្យ តំណាងមនុស្ស តម្លៃនៃប្រជាធិបតេយ្យ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋនៃសង្គម។

សហភាពអន្តរសភា( IPU ) ធ្វើការយ៉ាងជិតដល់ដើម្បីប្រជាធិបតេយ្យ សន្តិភាព សមភាពយេនឌ័រ សិទ្ធិមនុស្ស ការផ្តល់អំណាចដល់យុវជន កិច្ចសន្ទនានយោបាយ និងច្រើនជាងនេះទៀត។ អង្គការមួយនេះក៏ដាក់ចេញផងដែរនូវចំណេះជំនាញ ដើម្បីបំផុសគំនិតឱ្យមានការចូលរួមរបស់ស្ត្រី សំឡេងភាគតិច យុវជនវ័យក្មេង ជនមានពិការភាព និងសំឡេងភាគតិចនៅក្នុងតំណាងប្រជាធិបតេយ្យ។ សភាគឺជាសរសរស្តម្ភនៃដំណើរការប្រជាធិបតេយ្យ។ពាក្យថាសភា«Parliament»មានប្រភពដើមចេញមកពីភាសាបារាំង «Parler»

មានន័យថា និយាយ។ សម្រាប់មនុស្សរាប់រយលាននាក់ ការតំណាងនយោបាយ(ការក្លាយជាសមាជិកសភា) គឺជាក្តីសុបិនមួយដែលពិបាកនឹងឈោងដល់។

សហភាពអន្តរសភា(IPU) តំណាងនូវសាមគ្គីភាពជាមួយសកម្មជន បុគ្គលិកសង្គម និងអ្នកដែលមានចំណាប់អារម្មណ៍ខ្លាំង ដែលប៉ងប្រាថ្នាស្ថិតក្រោមការគ្រប់គ្រងរបស់របបនាសម្ព័ន្ធ និងបទដ្ឋាននៃប្រជាធិបតេយ្យសភា។ ទិវាអន្តរជាតិសភា ក៏ដើរតួនាទីជាអ្នករំលឹកផងដែរ សម្រាប់យើងទាំងអស់គ្នាឱ្យខិតខំតស៊ូពុះពារ ដើម្បីទទួលបានភាពជាតំណាងល្អប្រសើរជាងមុន នៅក្នុងសាលនៃអំណាច។ គោលដៅដ៏សំខាន់របស់សភា គឺដើម្បីបញ្ចេញមតិរបស់អ្នក ទៅកាន់អ្នកដែលមិនអាចបញ្ចេញមតិបាន។ ការងារសភា គឺជាការងារមួយដ៏លំបាក ហើយដើម្បីអាចសម្រេចការងារនេះបាន លុះត្រាតែមានការចូលរួមពីប្រជាពលរដ្ឋទាំងមូល៕

*ព័ត៌មានសភាទ្វីបអឺរ៉ុប ២៨-០៦-២៣- ឈាវ សុផាត*

ប្រែសម្រួលពី៖ https://nationaltoday.com/international-day-of-parliamentarism/

# International Day of Parliamentarism – June 30, 2023

International Day of Parliamentarism is observed on June 30 to honor the parliamentary systems of governance. First observed by a United Nations General Assembly Resolution in 2018, the day recognizes the unique and enduring system of parliamentary democracy as being the standard for political representation. The day also recognizes how a parliamentary system can conduct self-evaluations to take stock of progress, identify challenges, and formulate ways to address them.

## HISTORY OF INTERNATIONAL DAY OF PARLIAMENTARISM

The International Day of Parliamentarism is the annual celebration of the parliamentary system of governance. The day honors the founding values of a parliamentary system and the promise of political representation to billions of people. The United Nations General Assembly recognizes the role of parliaments in ensuring greater accountability and transparency of the people in power. International Day of Parliamentarism marks the anniversary of the Inter-Parliamentary Union (I.P.U.).

Established in 1889 as the formal representation of the parliamentary systems of governance, the I.P.U. is a global organization that works to promote democratic governance, human representation, democratic values, and the civil aspirations of a society.

The I.P.U. does critical work for democracy, peace, gender equality, human rights, youth empowerment, political dialogue, and much more. The organization also issues toolkits to inspire the participation of women, minorities, young people, disabled people, and minorities in representative democracy.

Parliaments are the cornerstone of functioning democracies. The word originates from the French word ‘parler,’ which means ‘to talk.’ For millions of people, political representation is a far-fetched dream. The I.P.U. stands in solidarity with activists, social workers, and enthusiasts who wish to be governed by the structure and norms of parliamentary democracy. International Day of Parliamentarism also serves as a reminder for us to strive for better representation in the halls of power. The key goal of a parliament is to give your voice to the voiceless. The work is difficult, and can only be accomplished with the participation of the entire citizenry.

https://nationaltoday.com/international-day-of-parliamentarism/